ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 11 / 2015
ម៉ោង (Time/Heure) : 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Uch Arun

002/19-09-2007-ECCC/TC
E1/338

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ២៧ ខែ សីហា ឆ្នាំ ២០១៥

## សវនាការលើភ័ស្តុតាង - ថ្ងៃ ៣១៩

រៀបចំដោយ៖ **ឯម ហ៊ីយ** និង **Maddalena GHEZZI**

| |
|---|
| **<u>កំណត់ហេតុអ្នកចូលរួម</u>** |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN, ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ លោក ឯម ហ៊ីយ, កញ្ញា Maddalena GHEZZI |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Travis FARR, លោក William SMITH, លោក Vincent de WILDE d'ESTMAEL, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក លីវ សុវណ្ណា, លោក សុន អរុណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, កញ្ញា ជេត វណ្ណលី, លោក វ៉ែន ពៅ, លោក ពេជ អង្គ |
| សាក្សី/ដើមបណ្តឹង៖ គ្មាន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖ កញ្ញា ស្រី ណាក់, កញ្ញា ពេជ ចរិយា, កញ្ញា សុក សុភ័គមណីកា, លោក គ្រី តុងហ្វ, កញ្ញា Aphra LEE |

| **ពេលវេលាចូលទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.១៨ | បញ្ចប់ម៉ោង៖ ១១.៤៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៥១ | បញ្ចប់ម៉ោង៖ ១១.១៣ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០២ ម៉ោង និង ០៥ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.១៩ | ០៩.២២ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.២៨ | ០៩.៣០ |
| សារណារបស់ជនជាប់ចោទ និងភាគីទាក់ទងទៅនឹងការដកខ្លួនចេញរបស់មេធាវីការពារក្តីពីសវនាការលើឯកសារគន្លឹះ កាលពីនៅថ្ងៃទី ២៦ ខែសីហាឆ្នាំ ២០១៥ | នួន ជា<br>មេធាវី ការពារក្តី នួន ជា<br>ខៀវ សំផន<br>មេធាវីការពារក្តី ខៀវ សំផន<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>អង្គជំនុំជម្រះ<br>ក្រុមមេធាវីខៀវសំផន<br>អង្គជំនុំជម្រះ | ០៩.២៣<br>០៩.២៨<br>១០.០៤<br>១០.០៧<br>១០:៣២<br>១១:១៤<br>១១:២៣<br>១១:២៦<br>១១:៣០ | ០៩.២៨<br>១០.០៣<br>១០.០៧<br>១០.៣២<br>១០:៥០<br>១១:២៣<br>១១:២៦<br>១១:៣០<br>១១:៤៥ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

សារណារបស់ជនជាប់ចោទ និងភាគី ទាក់ទងទៅនឹងការដកខ្លួនចេញរបស់មេធាវីការពារក្ដី ពីសវនាការលើឯកសារគន្លឹះ កាលពីនៅថ្ងៃទី ២៦ ខែសីហាឆ្នាំ ២០១៥ (៩.២៣) ។

ជនជាប់ចោទ នួន ជា និង ខៀវ សំផន ទាំងពីរនាក់បានអានសារណារបស់ខ្លួនដើម្បីគាំទ្រដល់ក្រុមមេធាវីរបស់ខ្លួន ។ ក្រុមមេធាវីជាតិនិងអន្តរជាតិ នួន ជា និង ខៀវ សំផន បានធ្វើសារណាស្ដីពីហេតុផលសម្រាប់ការប្រព្រឹត្តរបស់ខ្លួនអំឡុងពេលសវនាការស្ដីពីការដាក់បង្ហាញឯកសារគន្លឹះកាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥។ ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានបញ្ជាក់ថា ខ្លួនបានជំទាស់ទៅនឹងការប្រើប្រាស់ឯកសារដែលបានមកពីការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង០០៤។ ចំណែកក្រុមមេធាវីការពារក្ដីនួន ជា បានបញ្ជាក់ថា ខ្លួនបានជំទាស់ទៅនឹងការប្រើប្រាស់កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហើយឯកសារនោះមិនមានគុណភាពដូច "ឯកសារ" សម្រាប់គោលបំណងនៃការដាក់បង្ហាញឯកសារគន្លឹះ(យោងទៅរកឯកសារ E315/1) ។ សហព្រះរាជអាជ្ញា ណិងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានឆ្លើយតប។

អង្គជំនុំជម្រះបានបញ្ជាក់ថា យើងនឹងធ្វើពិភាក្សាលើបញ្ហានេះ និងបានពន្យារពេលសវនាការ ព្រមទាំងបានកែប្រែកាលវិភាគសំរាប់សប្ដាហ៍ក្រោយ ចាប់ពីថ្ងៃអង្គារ ដល់ ថ្ងៃសុក្រ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃផ្ទៃក្នុង</u>**

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួន

ខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ (០៩.៣៦)។

- ពន្យារពេលសវនាការដើម្បីដោះស្រាយទៅលើបញ្ហាដែលបានលើកឡើង ដោយក្រុមមេធាវីការពារក្ដី រហូតដល់ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ (១១:៤០)។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញ ឱ្យបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ (១៥.៤៥)។

| <u>កាលវេលាសវនាការបន្ត</u> |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ ចាប់ផ្ដើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឯម ហ៊ីយ** **Maddalena GHEZZI**